Shinhan Bank

# លក្ខខណ្ឌ និងខចែងនៃគណនីប្រាក់បញ្ញើប្រចាំខែមានរយៈពេលកំណត់

## មាត្រា ១. ការអនុវត្តនៃ លក្ខខណ្ឌ និងខចែង

លក្ខខណ្ឌ និងខចែងទាំងនេះត្រូវបានអនុវត្តចំពោះប្រតិបត្តិការជាមួយ**ធនាគារ ស៊ិនហាន** (**ខេមបូឌា**) ម.ក, (តទៅនេះហៅថា "**ធនាគារ**") ក្រោម " **គណនីប្រាក់បញ្ញើប្រចាំខែមានរយៈពេលកំណត់**" (តទៅនេះហៅថា " **គណនី**" )។

## មាត្រា ២. បុគ្គលដែលអាចមានសិទ្ធិប្រើប្រាស់

គណនីនេះអាចប្រើប្រាស់បានសម្រាប់រូបវន្តបុគ្គល (ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ) និងសាជីវកម្ម។

## មាត្រា ៣. លក្ខខណ្ឌនៃគណនី

| ប្រភេទ | សេចក្ដីលម្អិត |
|---|---|
| **ប្រភេទគណនី** | ប្រាក់បញ្ញើមានរយៈពេលកំណត់ |
| **ការដាក់ប្រាក់ដំបូង** | ១០.០០ដុល្លារ/ ៤០,០០០រៀល |
| **រូបិយប័ណ្ណ** | ដុល្លារ/រៀល |
| **រយៈពេល** | ៦ខែ / ១២ខែ/ ២៤ខែ/ ៣៦ខែ |
| **អត្រាការប្រាក់** | អនុវត្តដោយផ្អែកលើអត្រាការប្រាក់ស្តង់ដារដែលចេញដោយធនាគារ<br>(អាចផ្ទៀងផ្ទាត់តាមរយៈគេហទំព័រ៖ www.shinhan.com.kh) |
| **លក្ខខណ្ឌធ្វើប្រតិបត្តិការ** | ▪ មិនអាចដកប្រាក់បញ្ញើមានរយៈពេលកំណត់ដោយប្រើប្រាស់កាតអេធីអឹមបានឡើយ<br>▪ មិនអាចធ្វើការទូទាត់ទៅអោយភាគីទីបីដូចជាការទូទាត់ទំនិញ ឬ សេវាកម្មផ្សេងៗ |
| **ការទូទាត់ការប្រាក់** | ការទូទាត់ការប្រាក់ត្រូវធ្វើឡើងចាប់ពីថ្ងៃបិទគណនី ដោយផ្អែកលើចំនួនប្រាក់បញ្ញើ អត្រាការប្រាក់ និងរយៈពេលស្របតាមកិច្ចព្រមព្រៀង។ |
| **លក្ខខណ្ឌបន្ត** | មិនបន្ត ផ្ទេរទៅ (គណនីដាក់ប្រាក់បញ្ញើតាមតម្រូវការ) |
| **ប្រភេទនៃការដាក់ប្រាក់បញ្ញើ** | ដាក់ប្រាក់បញ្ញើប្រចាំខែ<br>(រហូតដល់ចំនួននៃប្រាក់ដើមនៅក្នុងកិច្ចសន្យាទៅតាមរយៈពេលកំណត់) |
| **វិធីសាស្ត្រក្នុងការដាក់ប្រាក់** | ▪ ដាក់សាច់ប្រាក់ទៅតាមបញ្ជរបង់ប្រាក់/ការផ្ទេរប្រាក់<br>▪ និងការផ្ទេរដោយស្វ័យប្រវត្តិ |

| | |
|---|---|
| **ពន្ធលើប្រាក់ចំណូលនៃការប្រាក់** | ៦% សំរាប់និវាសនជន/ ១៤% សំរាប់អនិវាសនជន |
| **ការដាក់ប្រាក់បញ្ញើ** | គ្រប់សាខានៃធនាគារស៊ិនហាន |
| **អត្ថប្រយោជន៍បន្ថែម** | មិនគិតកំរៃសេវាវិញ្ញាបនប័ត្រនៃការដាក់ប្រាក់បញ្ញើ/ អ៊ិនធើណិត ឬ សេវាធនាគារចល័ត |

## មាត្រា ៤. ប្រតិបត្តិការនៃប្រាក់បញ្ញើ

គណនីនេះត្រូវបានដំណើការជាគណនីប្រាក់បញ្ញើមានរយៈពេលកំណត់។

## មាត្រា ៥. ការទូទាត់ការប្រាក់

១. ការប្រាក់ត្រូវគណនាជាប្រចាំថ្ងៃ (វិធីសាស្រ្តមូលដ្ឋាន ៣៦០ថ្ងៃ)
២. ទូទាត់ការប្រាក់នៅពេលដែលបញ្ចប់/បិទៈ

- ដល់កាលកំណត់ៈ
  - ការទូទាត់ត្រូវបានធ្វើឡើងជាមួយប្រាក់ដើម និង ការប្រាក់។
  - បើសិនដល់រយៈពេលកំណត់ចំថ្ងៃចុងសប្តាហ៍ បុណ្យឬឈប់សម្រាក, គណនីនិងត្រូវបិទនៅថ្ងៃចុងសប្តាហ៍ បុណ្យ ឬឈប់សម្រាកនោះ ស្របតាមការបរិច្ឆេទដល់រយៈពេលកំណត់។
- មុនកាលកំណត់ៈ
  - ការទូទាត់ត្រូវបានផ្តល់ជូនមុនកាលកំណត់ (ការដកប្រាក់បញ្ញើជាផ្នែកមិនត្រូវបានអនុញ្ញាត) ក្នុងករណីបញ្ចប់/បិទមុនកាលកំណត់, ការទូទាត់និងផ្តល់បញ្ចប់អតិថិជនទាំងប្រាក់ដើមនិងការប្រាក់ដែលបានអនុវត្តទៅតាមការប្រាក់នៃគណនីដាក់ប្រាក់បញ្ញើតាមតម្រូវការ។

## មាត្រា ៦. ការបន្តបន្ទាប់ពីរយៈពេលកំណត់

គណនីនេះមិនអនុញ្ញាតអោយបន្តរយៈពេលកំណត់ទេ ហើយនៅពេលដល់រយៈពេលកំណត់ប្រាក់ដើមនិងការប្រាក់នឹងត្រូវផ្ទេរទៅគណនីដាក់ប្រាក់បញ្ញើតាមតម្រូវការដែលបានកត់ត្រា។

# លក្ខខណ្ឌ និងខខចែងសម្រាប់គណនីសន្សំប្រចាំខែមានរយៈពេលកំណត់

## មាត្រា ១. វិសាលភាពនៃការអនុវត្ត

១. គណនីសន្សំប្រចាំខែមានរយៈពេលកំណត់ "គណនី" មានន័យថាជាគណនីសន្សំដែលអតិថិជនអាចដាក់ទឹកប្រាក់ចំនួនណាមួយក៏បានចូលទៅក្នុងគណនីជាប្រចាំខែ ឬដោយសេរីក្នុងរយៈពេលជាក់លាក់ណាមួយ។
២. រាល់ចំណុចដែលមិនមានបញ្ជាក់នៅក្នុងលក្ខខណ្ឌ និងខចែងទាំងនេះនឹងត្រូវគ្រប់គ្រងដោយ "លក្ខខណ្ឌ និងខចែងទូទៅ" សម្រាប់ប្រតិបត្តិការប្រាក់បញ្ញើ។

## មាត្រា ២. ការដកប្រាក់

ប្រាក់បញ្ញើនៅក្នុងគណនី (ប្រាក់បញ្ញើ) អាចដកបានតាមការស្នើសុំរបស់អតិថិជនគ្រប់ពេលមុនឬបន្ទាប់ពីរយៈពេលកំណត់។ ក្នុងករណីដែលអតិថិជនស្នើសុំដកប្រាក់បញ្ញើមុនរយៈពេលកំណត់ ដោយសារមូលហេតុចាំបាច់ណាមួយ ធនាគារក៏អាចអនុញ្ញាតឱ្យដកប្រាក់បានដែរ។

## មាត្រា ៣. ការដាក់ប្រាក់សន្សំប្រចាំខែមានរយៈពេលកំណត់

អតិថិជនត្រូវដាក់ប្រាក់សន្សំចូលទៅក្នុងគណនីជាប្រចាំខែតាមកាលបរិច្ឆេទនិង រយៈពេលដាក់ប្រាក់ដែលបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យា។

## មាត្រា ៤. អត្រាការប្រាក់

១. ការប្រាក់លើប្រាក់បញ្ញើត្រូវកំណត់តាមរយៈពេលនៃការដាក់ប្រាក់ដែលបានព្រមព្រៀងគ្នា ដោយផ្អែកលើអត្រាការប្រាក់ដែលប្រកាសដោយធនាគារនៅកាលបរិច្ឆេទនៃការដាក់ប្រាក់បញ្ញើ ហើយការប្រាក់ត្រូវទូទាត់រួមជាមួយនិងប្រាក់បញ្ញើដើមបន្ទាប់ពីដល់កាលកំណត់។
២. ក្នុងករណីដែលអតិថិជនដាក់ប្រាក់សន្សំប្រចាំខែមានកំណត់ក្នុងកាលបរិច្ឆេទដែលបានព្រមព្រៀងគ្នាសម្រាប់ខែនីមួយៗ, ធនាគារត្រូវទូទាត់ចំនួនប្រាក់បញ្ញើសរុបដោយយោងលើ "ប្រាក់បញ្ញើដើម" បូកជាមួយនឹងការប្រាក់ "ចំនួនកិច្ចសន្យា" ដែលគណនាដោយផ្អែកលើគណនីសន្សំនីមួយៗសម្រាប់រយៈពេលចាប់ពីថ្ងៃដាក់ប្រាក់បញ្ញើរហូតដល់កាលបរិច្ឆេទដល់កាលកំណត់ ក្នុងអត្រាការប្រាក់ដូច អត្រាការប្រាក់គណនីសន្សំប្រកាសដោយធនាគារ។
៣.ប្រសិនបើអត្រាការប្រាក់អនុវត្តចំពោះប្រាក់បញ្ញើជាអត្រាការប្រាក់បន្ថែម អត្រាការប្រាក់ដែលបានផ្លាស់ប្តូរត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការផ្លាស់ប្តូរនោះ។

## មាត្រា ៥. ការប្រាក់សម្រាប់គណនីបិទមុនកាលកំណត់ និងគណនីបិទក្រោយកាលកំណត់

១. ប្រសិនបើការស្នើសុំដកប្រាក់របស់អតិថិជនធ្វើឡើងបន្ទាប់ពីដល់កាលកំណត់ ធនាគារត្រូវទូទាត់ការប្រាក់ដោយផ្អែកលើរយៈពេលនឹងអត្រាការប្រាក់ក្នុងកិច្ចសន្យា ហើយអត្រាការប្រាក់បន្ថែមដែលបង្គរចាប់ពីកាលបរិច្ឆេទដល់កំណត់រហូតដល់កាលបរិច្ឆេទនៃការដកប្រាក់ជាក់ស្តែង ត្រូវបានគណនាតាមអត្រាការប្រាក់នៃគណនីសន្សំដែលប្រកាសដោយធនាគារ។
២. ប្រសិនបើអតិថិជនស្នើសុំដកប្រាក់មុនកាលកំណត់ ធនាគារត្រូវបង់ការប្រាក់ដែលបង្គរចាប់ពីថ្ងៃដាក់ប្រាក់បញ្ញើរហូតដល់កាលបរិច្ឆេទមុនថ្ងៃដកប្រាក់ ដោយគណនាអត្រាការប្រាក់តាមអត្រាការប្រាក់នៃគណនីសន្សំដែលបានប្រកាសដោយធនាគារ។

## មាត្រា ៦. លក្ខខណ្ឌពិសេសសម្រាប់គណនីសន្សំប្រចាំខែមានរយៈពេលកំណត់

១. គណនីសន្សំប្រចាំខែមានរយៈពេលមិនកំណត់ គឺជាគណនីសន្សំដែលអាចដាក់ប្រាក់ចំនួនណាមួយក៏បានចូលទៅក្នុងគណនីបានគ្រប់ពេលនៅក្នុងរយៈពេលជាក់លាក់ណាមួយ។
២. ចំនួនទឹកប្រាក់ដែលត្រូវទូទាត់នៅពេលដល់កាលកំណត់នៃគណនីសន្សំប្រចាំខែមិនកំណត់ ជាប្រាក់បញ្ញើដំបូងរួមជាមួយនិងការប្រាក់សរុបនៃគណនីសន្សំប្រចាំខែមិនកំណត់ ដែលគណនាចាប់ពីថ្ងៃដាក់ប្រាក់បញ្ញើរហូតដល់កាលកំណត់។

## មាត្រា ៧. ការផ្អាក ការបិទ ការបង្កកគណនី

១. ម្ចាស់គណនី/បុគ្គលដែលមានសិទ្ធអាចស្នើសុំការបញ្ចប់/បិទគណនីដោយទៅកាន់ធនាគារដោយផ្ទាល់ដោយភ្ជាប់ជាមួយនឹងឯកសារពាក់ព័ន្ធ ដោយមិនរាប់បញ្ចូលប្រាក់បញ្ញើមានរយៈពេលកំណត់ ដែលបានបើកតាមរយៈអនឡាញ ដែលអាចបញ្ចប់/បិទគណនីតាមរយៈការទៅកាន់ធនាគារ ឬក៏តាមរយៈអនឡាញ ។
២. ធនាគារអាចផ្អាកគណនី ឬប្រតិបត្តិការធនាគារណាមួយនៃគណនីរបស់អតិថិជនដោយមិនចាំបាច់ជូនដំណឹងជាមុននៅក្នុងករណីដូចខាងក្រោម៖

ក. អតិថិជនមិនគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងអស់ទាក់ទងនឹងប្រតិបត្តិការគណនី ដូចជាច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ខ. អតិថិជនបានរំលោភលើបទប្បញ្ញត្តិនៃច្បាប់ជាធរមាននៅក្នុងប្រទេសកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត ទាំងដោយផ្ទាល់ និងដោយប្រយោលពាក់ព័ន្ធនឹងការហាមឃាត់បុគ្គល ឬអង្គភាពដែលបានកំណត់ ឬសកម្មភាពខុសច្បាប់ ឬការផ្ទេរប្រាក់ចេញ-ចូលជាមួយប្រទេសដែលជាប់ការដាក់ទណ្ឌកម្ម។

## មាត្រា ៨. ព័ត៌មានអតិថិជន និងការផ្ទៀងផ្ទាត់

១. អតិថិជនត្រូវជូនដំណឹងដល់ធនាគារអំពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋាន លេខទូរស័ព្ទ ឬអាសយដ្ឋានអ៊ីមែល។ដើម្បីធានាថាធនាគារនឹងចែករំលែកឯកសារសំខាន់ៗទាំងអស់ដែលទាក់ទងនឹងព័ត៌មានគណនីរបស់អតិថិជនទៅកាន់អាសយដ្ឋាន និងលេខទំនាក់ទំនងដែលត្រឹមត្រូវ។

២. រាល់ព័ត៌មានឯកជនភាពទាំងអស់របស់អតិថិជនត្រូវរក្សាទុកជាសម្ងាត់ ហើយនឹងត្រូវបានរក្សាទុកដោយសុវត្ថិភាពដោយធនាគារ។

## មាត្រា ៩. ច្បាប់ និងបទបញ្ញត្តិនៃស្ថាប័នពាក់ព័ន្ធ

អតិថិជនបានយល់ព្រមថា ចំពោះការបន្ថែម និងមិនប៉ះពាល់ដល់សិទ្ធដែលមានក្នុងលក្ខខណ្ឌ និងខចែង។ លក្ខខណ្ឌ និងខចែងនេះនឹងត្រូវគ្រប់គ្រង និងអនុលោមតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលធ្វើ កំណែទំរង់ដែលចេញដោយធនាគារជាតិនៃកម្ពុជា ។ ច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ រឺមិនពាក់ព័ន្ធផ្សេងទៀតដែលមានអំណាចដោយច្បាប់នៃព្រះរាជាណាចក្រនៃកម្ពុជា។

ខ្ញុំទទួលស្គាល់ថាបានអានលក្ខខណ្ឌខាងលើតាមកាលបរិច្ឆេទនៃថ្ងៃនេះ ហើយខ្ញុំនឹងទទួលត្រូវ និងដឹងពីកត្តាហានិភ័យដែលមាននៅក្នុងលក្ខខណ្ឌទាំងនេះ។

# INSTALLMENT DEPOSIT TERMS AND CONDITIONS

## Article 1. Application of Terms and Conditions

These terms and conditions apply to transactions with **Shinhan Bank (Cambodia) Plc,** (hereinafter refer to as the **"Bank"**) under **"Installment Deposit Account"** (hereinafter refer to as the "Account".

## Article 2. Eligible for Subscription

This account is available for individual (age 18 or older), and corporation.

## Article 3. Product Feature

| Categories | Contents |
|---|---|
| Product Type | Installment Deposit |
| Initial Deposit | USD10.00/KHR40,000 |
| Currency | USD/KHR |
| Tenor | 6months/ 12months/ 24months/ 36 months |
| Interest Rate | Applied based on Standard Interest rate announced by the Bank (can inquiry through website: www.shinhan.com.kh) |
| The ways of Transaction | ▪ Cannot withdraw their installment deposits by using ATM Card<br>▪ Cannot make payments to third parties as payment for goods or services and others |
| Interest Payment | Interest payment shall be proceeded from the closing date based on the deposit amount, agreed of interest rate and tenor |
| Renewal Condition | Not renewal-transfer to DDA (Demand Deposit Account) |
| Installment Cycle | Monthly deposit<br>(up to contract principle amount until the maturity) |
| Way to Deposit | ▪ Counter by Cash/Transfer<br>▪ Automatic Transfer |

| | |
|---|---|
| Interest Income Tax | 6% for Resident/14% for Non-Resident |
| Access to Deposit | All SBC branches |
| Additional Benefit | Free Certificate of Deposit/Internet or Mobile Banking |

## Article 4. Operation of Deposits

This account is operated as installment deposit.

## Article 5. Interest Payment

1. Interest to be calculated on a daily basis (360 days basis method)
2. Interest Payment when termination/closure:
   - At Maturity:
     - Payment is made with principle and conventional interest.
     - If the maturity date is on weekend or holiday, the Account will be closed on weekend or holiday based on the maturity date.
   - Before maturity:
     - Payment can be made fully prior to the maturity (partial withdrawals is not allowed), In the case termination/closure before maturity, payment is made to the Customer With principle; and the interest rate applied as saving account's interest rate.

## Article 6. Extension of Maturity

The Account is not allowed for extension of maturity and will be transferred to registered Demand Deposit Account when reach maturity date.

# TERMS AND CONDITIONS FOR INSTALLMENT DEPOSIT ACCOUNT

## Article 1. Scope of Application

1. The Installment deposit account the "Account" shall mean a deposit account under which an agreed or unspecified amount is deposited into the Account in monthly or freely installments for a specified period.
2. Matters not specified in these Terms and Conditions shall be governed by the "General Terms and Conditions" for deposit transactions.

## Article 2. Time of Withdrawal

The deposit in the Account the "Deposit" may be withdrawn upon the Customer's request at any time after the maturity date; provided that in case the Customer requests for withdrawal of the Deposit due to unavoidable causes prior to maturity, the Bank shall allow the withdrawal.

## Article 3. Deposit of Installments

The Customer shall deposit the installments into the Account on the agreed upon date during the agreed-upon deposit period on a monthly basis.

## Article 4. Interest

1. Interest on the Deposit shall be determined by the agreed deposit period based on the applicable interest rate announce by the Bank as the date of deposit and shall be paid together with the principle after the maturity date.
2. In case the Customer deposits monthly installments in the agreed-upon date for each month. the Bank shall pay the accumulated amount of the deposits refer to the "Principle" plus the interest the "Contract Amount" calculated with respect to each installment for the period from the deposit date to the day immediately preceding the maturity date at the interest rate as saving account interest rate announce by the Bank.
3. If the interest rate applicable to the deposit is a preferential interest rate, the changed interest rate shall apply from the date of change.

## Article 5. Pre-Maturity Termination & Post-Maturity Interest Rate

1. If the Customer's request for withdrawal is made after the maturity date, the Bank shall pay the interest based on the contract period with the contract interest rate, and the additional interest rate accrued from the maturity date to the date immediately preceding the date of actual withdrawal, calculated the interest rate as per saving account interest rate announce by the Bank.
2. If the Customer's request for withdrawal is made prior to the maturity date, the Bank shall pay the interest accrued from the date of deposit to the date immediately preceding the date of withdrawal, calculated the interest rate as saving account interest rate announce by the Bank.

## Article 7. Special Provisions for Free Installment Deposit Account

1. The free installment deposit account shall mean a deposit account under which any amount of installment may be deposited at any time during the agreed upon deposit period.
2. The amount payable on the maturity date of the free installment deposit account shall be the principle together with the sum of interest on each of the installments for the period from the deposit date of each installment to the date immediately preceding the maturity date at the interest rate that announce by the Bank as the open date.

## Article 8. Suspension, Close, Freeze of the Account

1. Account Holder(s)/Authorized Person(s) can request for the termination/closure by visit the Bank with related documents exclude Term Deposit open through online channels that can be proceed separately by The Customer.
2. The Bank may suspend or the banking transaction any of the Customer's account(s) without prior notice in the following cases
   a) The Customer do not comply with all applicable laws, rules and regulations in connection with account operation such as Law on Anti-Money Laundering and Combating the Financial of Terrorism.
   b) The Customer violated provisions of applicable law in Cambodia or any other country both directly and indirectly involve with any designated individual or entity prohibition or any illegal activities or transfer in-out with sanction countries.

## Article 9. Customer Information and Verification

1. The Customer shall notify the Bank of any change in current address, telephone number of E-mail address, this will ensure that the Bank to share all important documents related to the Customer's account information to the correct address and contact.
2. All privacy information of the Customer shall be kept in strict confident and will be securely held by the Bank.

## Article 10. Rules and Regulations of Related Bodies

You hereby agree that in addition and without prejudice to any of the terms and conditions herein, where applicable the terms and conditions herein shall be governed by and subjected to the rules, regulations and guidelines from time to time issued by National Bank of Cambodia, and other relevant, and other relevant bodies whether or not such rules, regulations and guidelines have the force of laws.

My signature acknowledges that I have read the terms and conditions above as the date of today, and I am aware of the risk factors contained in these terms and conditions.